ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៨៤

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩

សាលដីកា

លេខ ៤០ VIII

ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម (របាយការណ៍)

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់លោក[redacted]តាន់ ជាមេធាវីតំណាង ឱ្យជនត្រូវចោទឈ្មោះ[redacted]សុខជា ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាលេខ ៨៧ "ក្រIII.ឃ" ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖



Scanned with CamScanner

-ជនត្រូវចោទឈ្មោះ [redacted] សុខជា ភេទប្រុស កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧២ ជាតិខ្មែរ មុខរបរជាវេជ្ជបណ្ឌិតឯកទេសជម្ងឺកុមារ នៃមជ្ឈមណ្ឌលលើកកម្ពស់សុខភាពនៅក្រសួងសុខាភិបាល មានទីកន្លែងកំណើតសង្កាត់លេខ ៥ ក្រុងភ្នំពេញ ។ មានទីលំនៅមុនពេលចាប់ឃុំខ្លួននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន ។ (នៅក្នុងការឃុំខ្លួន)។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៧៧៤ "ល" ជ.ឃ.ជ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ។ បច្ចុប្បន្នកំពុងជាប់ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ។

-មានលោកមេធាវី [redacted] នារ៉ា ជាអ្នកការពារ ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទឆបោក ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី៖**

១.ឈ្មោះ [redacted] ចាន់ធី ភេទប្រុស កើតឆ្នាំ១៩៧០ ជាតិខ្មែរ មុខរបរវេជ្ជបណ្ឌិត មានទីលំនៅសព្វថ្ងៃនៅផ្ទះ [redacted] រាជធានីភ្នំពេញ ។

-មានលោកមេធាវី [redacted] សុវត្ថិត្រា ជាអ្នកការពារ និងតំណាងឱ្យឈ្មោះ [redacted] ចាន់ធី ។

២.ឈ្មោះ [redacted] ចន្ធី ភេទស្រី កើតឆ្នាំ១៩៨០ ជាតិខ្មែរ មុខរបរជាបុគ្គលិកពេទ្យ មានទីលំនៅសព្វថ្ងៃ [redacted] ខេត្តត្បូងឃ្មុំ ។

៣.ឈ្មោះ [redacted] ឌីណាល់ ភេទប្រុស កើតឆ្នាំ១៩៨៥ ជាតិខ្មែរ មុខរបរគិលានុបដ្ឋាក មានទីលំនៅសព្វថ្ងៃនៅ [redacted] ខេត្តក្រចេះ ។

៤.ឈ្មោះ [redacted] គន្ធា ភេទស្រី កើតឆ្នាំ១៩៨២ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ [redacted] រាជធានីភ្នំពេញ ។



Scanned with CamScanner

**អំពីអង្គហេតុ៖**

កាលពីអំឡុងឆ្នាំ២០១៦ ឈ្មោះ [redacted] សុខជា បានអះអាងប្រាប់ឈ្មោះ [redacted] ចាន់ធី ថាខ្លួនស្គាល់អ្នកធំនៅក្រសួងនានា មានដូចជា៖ ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ ក្រសួងប្រៃសណីយ៍ និងក្រសួងកសិកម្ម ហើយអាចបញ្ចូលការងារក្នុងក្របខណ្ឌរដ្ឋបាន។ ដោយយកងារឯកឧត្តមនៃក្រសួងទាំងអស់នោះមកធ្វើការបោកបញ្ឆោតឱ្យឈ្មោះ [redacted] ចាន់ធី មានការជឿទុកចិត្ត ។ ដោយមានការជឿទុកចិត្ត ឈ្មោះ [redacted] ចាន់ធី ក៏បានប្រគល់ប្រាក់ឱ្យទៅឈ្មោះ [redacted] សុខជា ជាបន្តបន្ទាប់សរុបជាទឹកប្រាក់ទាំងអស់ចំនួន ៣៧៥.៥០០ (បីរយចិតសិបប្រាំពាន់ប្រាំរយ) ដុល្លារអាមេរិក ដើម្បីទទួលបានការងារក្របខណ្ឌរដ្ឋនៅក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ និងក្រសួងទេសចរណ៍ ។ បន្ទាប់ពីបានទទួលប្រាក់រួចមក ឈ្មោះ [redacted] សុខជា មិនបានយកប្រាក់ទាំងនោះទៅរត់ការយកការងារក្របខណ្ឌរដ្ឋនោះទេ បែរជាយកប្រាក់ទាំងនេះទៅចាយវាយជាប្រយោជន៍ផ្ទាល់ខ្លួន និងយកលេសភូតកុហក ពន្យារពេលចូលបម្រើការងារម្តងថាថ្ងៃនេះ ម្តងថាថ្ងៃនោះរហូត។

-បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៧៧៤ “ល” ដ.ឃ.ដ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ សម្រេចថា ៖

១.ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ [redacted] សុខជា ភេទប្រុស អាយុ ៤៧ ឆ្នាំ ទៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ។

២.ឱ្យប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ) និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

៣.ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

-បានឃើញ បណ្តឹងលេខ ៩០១២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ភារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ដែលប្តឹងមិនសុខចិត្តនឹងដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៧៧៤ “ល” ដ.ឃ.ដ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៨៦៣៧ “ល” ដ.ព.ស ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

មិនព្រមដោះលែងឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ភេទប្រុស អាយុ ៤៧ ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅសង្កាត់លេខ ៥ ក្រុងភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ ឡាយ សារឿន (រស់) ប្រពន្ធឈ្មោះ [redacted] (រស់) មានកូន ០១ នាក់។ ជានីតិជន ។ ទោសពីមុនគ្មាន។ នៅក្នុងការឃុំខ្លួន ។



Scanned with CamScanner

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១២១ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោក [redacted] ភារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ដែលប្តឹងមិនសុខចិត្តនឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៨៦៣៧ "ល" ដ.ព.ស ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សាលដីកាលេខ ៨៧ ក្រIII "ឃ" ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២១ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មេធាវី [redacted] ភារ៉ា ជាអ្នកការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែ បដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២.តម្កល់ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៨៦៣៧ "ល" ដ.ព.ស ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះ ពិភាក្សាដេញដោលជាអសាធារណៈ នៅថ្ងៃអង្គារ ១៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ និងប្រកាសជាអសាធារណៈ នៅថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] នារ៉ា ជាមេធាវីតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាលេខ ៨៧ "ក្រIII:ឃ" ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំដោយលើកឡើងដូចខាងក្រោមថា៖ យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] សុខជា បានប្រើឧបាយកលទុច្ចរិត ថាខ្លួនស្គាល់អ្នកធំនៅក្រសួងមួយចំនួនដូចជា ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ ក្រសួងប្រៃសណីយ៍ និងក្រសួងកសិកម្ម ដើម្បីបោកបញ្ឆោតជនរងគ្រោះ [redacted] ចាន់ធី ឱ្យប្រគល់ប្រាក់ចំនួន ៣៧៥.៥០០ (បីរយចិតសិបប្រាំពាន់ប្រាំរយ) ដុល្លារអាមេរិក សម្រាប់រត់ការចូលក្របខណ្ឌរដ្ឋ។ ក្រោយពីបានប្រាក់ជនត្រូវចោទបានយកប្រាក់នោះមកចាយជាប្រយោជន៍ផ្ទាល់ខ្លួន ។

-យល់ឃើញថា អំពើរបស់ជនត្រូវចោទជាបទឆបោក ដែលច្បាប់បានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសម្រេចតម្កល់ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ មានសំអាងហេតុស្របតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ។ ហេតុដូច្នេះ តំណាងមហាអយ្យការសូមទុកជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។



Scanned with CamScanner

+ជនត្រូវចោទឈ្មោះ [redacted] សុខជា បានឆ្លើយថា ខ្លួនបានព្រមព្រៀងសងប្រាក់ទៅឱ្យឈ្មោះ [redacted] ចាន់ធី ចំនួន ១១៦.០០០ ដុល្លារអាមេរិក ហើយឈ្មោះ [redacted] ចាន់ធី ជាអ្នកយកលុយនោះទៅសងបន្តឱ្យភាគីទាំងនោះ ។ ចំពោះការសង ខ្លួនបានផ្ញើឱ្យតាមរយៈវីងបានចំនួន ២ ខែ ។ ក្រៅពីនោះម្ដាយរបស់ខ្លួនបានយកទៅសងផ្ទាល់នៅចំពោះមុខសមត្ថកិច្ច។ ខ្លួនបានសងគាត់ជាបន្តបន្ទាប់ក្នុងរយៈពេល ១១ ខែ បានចំនួន ៥.០០០ ដុល្លារអាមេរិក។ ខ្លួនគ្មានចេតនាគេចវេសមិនសងប្រាក់គាត់នោះទេ តែដោយហេតុថា ខ្លួនមានការខ្វះខាតលុយ ព្រោះម្ដាយខ្លួនមានជំងឺ ប៉ុន្តែការសងប្រាក់ គឺខ្លួននៅតែសងជាបន្តបន្ទាប់ដដែល ។ ខ្លួនសំណូមពរ សុំតុលាការមេត្តាឱ្យខ្លួនបាននៅក្រៅឃុំជាបណ្ដោះអាសន្ន។

+លោក [redacted] ភារ៉ា ជាមេធាវីការពារឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ [redacted] ចាន់ធី ហើយឈ្មោះ [redacted] ចាន់ធី ក៏បានពឹងពាក់ឱ្យកូនក្ដីរបស់ខ្លួនជាអ្នករត់ការចូលក្របខណ្ឌរដ្ឋ ដោយបានព្រមព្រៀងប្រគល់ប្រាក់ចំនួន ១១៦.០០០ ដុល្លារអាមេរិក ឱ្យមកកូនក្ដីខ្លួន។ ប៉ុន្តែដោយធ្វើការពុំបានសម្រេច ឈ្មោះ [redacted] ចាន់ធី ក៏បានប្ដឹងកូនក្ដីរបស់ខ្លួនទៅក្រសួងមហាផ្ទៃ ក៏ត្រូវបានឃាត់ខ្លួន ដោយបានចុះកិច្ចសន្យា និងបានសងប្រាក់ទៅឈ្មោះ [redacted] ចាន់ធី បានចំនួន ៣.០០០ ដុល្លារអាមេរិក ផងដែរ ។ ប្រាក់ដែលនៅសល់កូនក្ដីខ្លួននៅតែបន្តសងជាបន្តបន្ទាប់ទៅតាមការព្រមព្រៀងក្នុងកិច្ចសន្យាបានចំនួន ១១ ខែ រួចមកហើយ ដែលមានម្ដាយជាអ្នកជួយសង។ ដោយសារតែម្ដាយត្រូវទៅពិនិត្យជំងឺនៅឯប្រទេសថៃ ទើបនាំឱ្យមានការយឺតយ៉ាវក្នុងការសងប្រាក់។ ស្រាប់តែឈ្មោះ [redacted] ចាន់ធី បានទៅប្ដឹងនៅក្រសួងមហាផ្ទៃម្ដងទៀត ដោយលើកឡើងអំពីចំនួនទឹកប្រាក់ច្រើនជាងមុន ដែលជាមូលហេតុធ្វើឱ្យកូនក្ដីរបស់ខ្លួនត្រូវបានចាប់ខ្លួនរួចបញ្ជូនមកកាន់តុលាការ ។ កូនក្ដីរបស់ខ្លួនជាមន្ត្រី ធ្វើការនៅក្រសួងសុខាភិបាល មានទីលំនៅពិតប្រាកដ គាត់មានម្ដាយចាស់ជរានៅតែម្នាក់ឯង និងមានប្រពន្ធ ព្រមទាំងកូនតូច ត្រូវការអ្នកចិញ្ចឹមបីបាច់ មើលថែរក្សា។ ក្នុងសំណុំរឿងនេះកូនក្ដីខ្លួនមានកាតព្វកិច្ចក្នុងការសងប្រាក់ជាបន្តបន្ទាប់តាមកិច្ចសន្យា ។ សំណូមពរ ស្នើសុំឱ្យតុលាការអនុញ្ញាតឱ្យកូនក្ដីខ្លួនបាននៅក្រៅឃុំជាបណ្ដោះអាសន្ន ។

+លោក [redacted] សុភ័ក្ត្រា ជាមេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ធី បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ភាគីឈ្មោះ [redacted] ទីណាល់ និងឈ្មោះ [redacted] គន្ធា បានប្រគល់ប្រាក់ចំនួន ២៥៥.៥០០ ដុល្លារអាមេរិក ទៅឱ្យឈ្មោះ [redacted] សុខជា ដើម្បីយកទៅរត់ការចូលក្របខណ្ឌរដ្ឋ ។ កូនក្ដីរបស់ខ្លួនបានព្រមព្រៀងជាមួយឈ្មោះ [redacted] សុខជា នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ក្នុងការសងប្រាក់។ កូនក្ដីខ្លួនបានទទួលប្រាក់តាមរយៈវីងខ្លះ និង តាមរយៈមន្ត្រីនគរបាលយុត្តិធម៌ខ្លះ បានសរុបចំនួន ៣៣.០០០ ដុល្លារអាមេរិក ប៉ុណ្ណោះ នៅសល់ចំនួន ៨៣.០០០ ដុល្លារអាមេរិកទៀត ។ កូនក្ដីខ្លួនបានព្យាយាមទាក់ទងទៅគាត់ ([redacted] សុខជា) ជាច្រើនលើកច្រើនសា ប៉ុន្តែមិនអាចទាក់ទងបាន។ ម្យ៉ាងទៀតភាគីពាក់ព័ន្ធបានទាមទារប្រាក់ពីកូនក្ដីរបស់ខ្លួនដែរ ទើបកូនក្ដីខ្លួនប្ដឹងជនជាប់ចោទបន្ត ។ ចំពោះនីតិវិធីនៅសាលាដំបូងចៅក្រមជំនុំជម្រះបានដាក់ពេលសវនាការរួចហើយ ប៉ុន្តែមេធាវីរបស់ជនជាប់ចោទបានដាក់ពាក្យសុំលើកពេល ។ ដូចនេះ ជនជាប់ចោទពិតជាមានចេតនាទុច្ចរិតក្នុងការគេចវេសមិនសងប្រាក់មកឱ្យកូនក្ដីរបស់ខ្លួនពិតមែន។ សំណូមពរ សុំតុលាការមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។



Scanned with CamScanner

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនត្រូវចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ។
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

១- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់មេធាវី [redacted] ភារ៉ា ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧,មាត្រា ៤១៨,មាត្រា ៤២០ និងមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- យល់ឃើញថា ជនត្រូវចោទឈ្មោះ សេក សុខជា ភេទប្រុស កើតឆ្នាំ១៩៧២ ត្រូវបានចៅក្រមស៊ើបសួរដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឆបោក បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ១(មួយ)ឆ្នាំ ដូច្នេះតុលាការអាចឃុំខ្លួនជាបណ្តោះអាសន្នបាន ស្របតាមបទប្បញ្ញត្តិមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងទៀត តាមការលើកឡើងរបស់មេធាវីការពារក្តីឱ្យជនត្រូវចោទ ក៏ដូចជាលោកមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែរ បានបញ្ជាក់ថា រឿងក្តីនេះត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញបានចេញដីកា ដំណោះស្រាយ បញ្ជូនសំណុំរឿងទៅជំនុំជម្រះហើយ។

៣- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៨៧ ក្រ III "ឃ" ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ ។

## ហេតុដូច្នេះ
## សម្រេចសេចក្តី

១. បដិសេធបណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់មេធាវី [redacted] ភារ៉ា ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] សុខជា ក្នុងការប្តឹងសាទុក្ខ ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៨៧ ក្រ III "ឃ" ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner